**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខៈ......០៦៦.....[illegible].៣

# សេចក្តីជូនដំណឹង

## ស្តីពី ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីសំណើបែងចែកភាគលាភ ប្រចាំឆ្នាំ២០២៥ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ជ្រាបថា យោងតាមការសម្រេច របស់ក្រុមប្រឹក្សាភិបាល នាកិច្ចប្រជុំវិសាមញ្ញលើកទី១ ឆ្នាំ២០២៦ (ប្រជុំលើកទី២) របស់ក្រុមប្រឹក្សាភិបាល អាណត្តិទី៩ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ បានសម្រេចលើសំណើបែងចែកភាគលាភប្រចាំឆ្នាំ២០២៥ របស់ រ.ទ.ស.ភ ដែលមានលម្អិតដូចខាងក្រោម៖

- ប្រភេទនៃភាគលាភដែលត្រូវបែងចែក : សាច់ប្រាក់
- ប្រភពនៃភាគលាភ : ប្រាក់ចំណេញប្រចាំឆ្នាំ២០២៥
- ភាគលាភសរុបដែលត្រូវបែងចែក : ២៨.៧០១.១៤៣.៤៦០រៀល
  - ➢ ភាគលាភរបស់ រដ្ឋដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: ២៤.៣៩៥.៩៧១.៧១០រៀល
    *(គ្រោងនឹងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិសាមញ្ញលើកទី២ នាពេលខាងមុខ)*
  - ➢ ភាគលាភបែងចែកជូនភាគហ៊ុនិកឯកជន : **៤.៣០៥.១៧១.៧៥០រៀល**
- អនុបាតនៃការបែងចែកភាគលាភសរុប : ៣០,២២%
  - ➢ រដ្ឋដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : ២៥,៦៩%
    *(គ្រោងនឹងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិសាមញ្ញលើកទី២ នាពេលខាងមុខ)*
  - ➢ ភាគហ៊ុនិកឯកជន : **៤,៥៣%**
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **៣៣០រៀល**
- រយៈពេលនៃការបែងចែកភាគលាភ : ប្រចាំឆ្នាំ
- កាលបរិច្ឆេទអិចឌីវីដឹនដ៍ ឬអិចរាយឋ៍ (រំពឹងទុក) : ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៦
- កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ (រំពឹងទុក) : ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦
- កាលបរិច្ឆេទទូទាត់ភាគលាភ (រំពឹងទុក) : ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦
- កាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិកលើកទី១៤ របស់ រ.ទ.ស.ភ (រំពឹងទុក) : ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

❖ **សូមបញ្ជាក់៖**

សេចក្តីសម្រេចរបស់ក្នុងប្រឹក្សាភិបាល លើសំណើបែងចែកភាគលាភប្រចាំឆ្នាំ២០២៥ របស់ រ.ទ.ស.ភ នឹងត្រូវស្នើសុំការបោះឆ្នោតអនុម័តក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១៤ ដែលគ្រោងនឹងប្រព្រឹត្តនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦ នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមរយៈប្រព័ន្ធអនឡាញ (ZOOM)។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៥រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ចម្លងជូន៖**

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ

*"មេត្តាជ្រាប"*

- ឯកសារ-កាលប្បវត្តិ



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh